# សេចក្តីថ្លែងការណ៍រួមស្តីពី
# ការបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២២

ក្នុងទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានយើងជា ស្ថាប័នសារព័ត៌មាន និងអង្គការសង្គមស៊ីវិលមានរាយឈ្មោះនៅខាងក្រោមសូមអំពាវនាវ ដល់អាជ្ញាធរកម្ពុជាផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មាននិងឈប់ប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះទៀត។

ខណៈកម្ពុជាកំពុងរៀបចំស្វាគមន៍ប្រមុខរដ្ឋបរទេសអ្នកការទូតនិងប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិមកចូលរួមកិច្ចប្រជុំកំពូលអាស៊ានក្នុងខែនេះយើងជំរុញឱ្យអាជ្ញាធរធានាថាអ្នកសារព័ត៌មានមានសេរីភាពក្នុងការរាយការណ៍និងផ្សព្វផ្សាយព័ត៌មានដើម្បីបម្រើផលប្រយោជន៍សាធារណៈ។យើងក៏ជំរុញឱ្យមានវិធានការជាបន្ទាន់ដើម្បីធានាថារាល់ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពឯករាជ្យនិងតម្លាភាពលើឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មានត្រូវបានធ្វើឡើងដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះ។

ចាប់តាំងពីឆ្នាំ១៩៩៤ យ៉ាងហោចណាស់អ្នកសារព័ត៌មានចំនួន១៥នាក់ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជា។អ្នកសារព័ត៌មានចំនួន១២នាក់បានរាយការណ៍អំពីបញ្ហារសើបនៅពេលពួកគេត្រូវបានសម្លាប់ ហើយគ្មានជនល្មើសណាម្នាក់ត្រូវបាននាំមកផ្តន្ទាទោសឡើយ ក្នុងករណីទាំង១២នេះ។

ការយាយីនិងឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននៅតែជាក្តីបារម្ភខ្ពស់នៅឆ្នាំនេះ។ យោងតាមសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា(CamboJA)អ្នកសារព័ត៌មានចំនួន៥៧នាក់ត្រូវបានយាយីក្នុងរយៈពេល១០ខែចុងក្រោយនេះ(ពីខែមករាដល់ខែតុលាឆ្នាំ២០២២)។ក្នុងចំណោមអ្នកសារព័ត៌មានទាំង៥៧នាក់នេះ២៣នាក់ទទួលរងអំពើហិង្សានិងការគំរាម កំហែង១២នាក់ត្រូវបានចាប់ខ្លួន១២នាក់ប្រឈមនឹងការយាយីតាមផ្លូវតុលាការ៦នាក់ត្រូវបានឃុំខ្លួនដើម្បីសាកសួរនិងអាជ្ញាបណ្ណសារព័ត៌មានចំនួន៤ត្រូវបានដកហូត។

ការដំណើរការក្តីលើអតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី២រូបបានអូសបន្លាយរយៈពេល៥ឆ្នាំដោយរំលោភសិទ្ធិរបស់ពួកគេក្នុងការជំនុំជំរះក្តីឱ្យបានលឿននិងការរឹតត្បិតលើសេរីភាពក្នុងការធ្វើដំណើរ។

អ្នកសារព័ត៌មានកម្ពុជានិងបរទេសនៅឆ្នាំនេះបានជួបប្រទះនូវអំពើហិង្សាការយាយីនិងការបំភិតបំភ័យម្តងហើយម្តងទៀតពីអាជ្ញាធរនិងតួអង្គដទៃទៀតខណៈកំពុងរាយការណ៍អំពីកូដកម្មការងារដែលកំពុងបន្តរបស់បុគ្គលិកក្រុមហ៊ុនណាហ្គាវើលដ៍ក្នុងរាជធានីភ្នំពេញ។ អ្នកសារព័ត៌មានរបស់វីអូឌី (VOD) ចំនួន៥នាក់ត្រូវ

បានឃុំខ្លួនដោយអយុត្តិធម៌និងសាកសួរអស់រយៈពេលប្រមាណ៧ម៉ោងខណៈចុះយកព័ត៌មានអំពីការកាប់ឆ្ការ និងការដាំកូនឈើឡើងវិញនៅភ្នំតាម៉ៅ។

ការឃាឃីនិងការធ្វើទុក្ខបុកម្នេញលើអ្នកសារព័ត៌មានដែលកំពុងរាយការណ៍ដើម្បីជាប្រយោជន៍សាធារណៈ ធ្វើឱ្យប៉ះពាល់ដល់សេរីភាពនៃការបញ្ចេញមតិនិងសារព័ត៌មានគំរាមកំហែងដល់ការទទួលបានព័ត៌មានរបស់សាធារណជននិងមានការពិបាកសម្រាប់ឱ្យបុគ្គលមានអំណាចទទួលខុសត្រូវនូវអ្វីដែលខ្លួនបានប្រព្រឹត្ត។ លើសពីនេះពេលដែលអាជ្ញាធរមិនបានធ្វើការស៊ើបអង្កេតត្រឹមត្រូវនិងផ្តន្ទាទោសឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន វាជាសារមួយបង្ហាញថាឧក្រិដ្ឋកម្មបែបនេះត្រូវបានអនុញ្ញាត។

យើងថ្កោលទោសចំពោះនិទណ្ឌភាពនៃឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានដែលបាន ប្រព្រឹត្តនៅកម្ពុជា។ យើងអំពាវនាវឱ្យអាជ្ញាធរចាត់វិធានការជាក់ស្តែងដើម្បីធានាថាការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យនិងតម្លាភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារ ព័ត៌មានត្រូវបានធ្វើឡើងដែលជនល្មើសត្រូវបានផ្តន្ទាទោសហើយថាអ្នកសារព័ត៌មានដែលបានជួបប្រទះឧក្រិដ្ឋកម្មទាំងនេះទទួលបានយុត្តិធម៌។

យើងក៏សូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាចាត់វិធានការជាបន្ទាន់ដើម្បីធានាសុវត្ថិភាពអ្នកសារព័ត៌មានទាំងអស់ដែលកំពុងធ្វើការក្នុងប្រទេសកម្ពុជាដើម្បីឱ្យពួកគេអាចប្រើប្រាស់សេរីភាពបញ្ចេញមតិនិងសារព័ត៌មានដើម្បីបម្រើសាធារណជនដោយគ្មានការភ័យខ្លាច។

ជាយូរមកហើយ រដ្ឋាភិបាលបានខកខានក្នុងការនាំយកជនល្មើសដែលប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានមកផ្តន្ទាទោស។ ត្រូវតែបញ្ឈប់និទណ្ឌភាពបែបនេះ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖

អ្នកស្រី ឆន សុគន្ធា នាយិកានាយកដ្ឋានអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយនៃមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) តាមរយៈទូរសព្ទឬបណ្តាញ Signal លេខ (+៨៥៥) ៧៨២២៤៦៦ ឬតាមរយៈអ៊ីមែល csokunthea@ccimcambodia.org (ភាសាអង់គ្លេសនិងភាសារខ្មែរ)

លោក ណុប វី នាយកប្រតិបត្តិសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) តាមរយៈទូរសព្ទឬបណ្តាញ Signal លេខ (+៨៥៥) ១២៥១៩២៦១ ឬតាមរយៈអ៊ីមែល ed@camboja.net (ភាសាអង់គ្លេសនិងភាសាខ្មែរ)

សេចក្តីថ្លែងការណ៍នេះចូលរួមគាំទ្រដោយ៖

១. វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)

២. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
៣. សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ (CIWA)
៤. សមាគមកម្ពុជាការពារអ្នកកាសែត (CAPJ)
៥. សម្ព័ន្ធសហជីពកម្ពុជា (CATU)
៦. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
៧. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ(CCIM)
៨. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
៩. សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
១០. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
១១. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
១២. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុប
បំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ( NGO-CEDAW)
១៣. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
១៤. បណ្តាញយុវជនកម្ពុជា (CYN)
១៥. សមាគមមន្ត្រីរាជការស៊ីវិលឯករាជ្យ (CICA)
១៦. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស (CENTRAL)
១៧. សម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)
១៨. សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
១៩. គណៈកម្មាធិការដើម្បីការបោះឆ្នោតសេរីនិងយុត្តិធម៌នៅកម្ពុជា (COMFREL)
២០. អង្គការមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
២១. គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
២២. សហព័ន្ធសហជីពសេរីឯករាជ្យ (FUFI)
២៣. អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
២៤. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
២៥. សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ)
២៦. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនកាស៊ីណូ ណាហ្គាវើលដ៍ (LRSU)
២៧. ក្លឹបអ្នកសារព័ត៌មានបរទេសនៃកម្ពុជា (OPCC)
២៨. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព (PDP-Center)
២៩. សហភាពផ្ទះសាមគ្គី (SH)
៣០. តម្លាភាពកម្ពុជា (TIC)

៣១. មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)

៣២. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)